ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៧៦៦ អយក.ប្រក

# ប្រកាស

## ស្តីពី ការបើកសាលាបឋមសិក្សា វត្តព្រែកក្រើស ជាសាលាបឋមសិក្សា ពេញលក្ខណៈ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិត ស្នើសុំរបស់លោកប្រធានការិយាល័យអប់រំយុវជន និងកីឡា ស្រុកកំពង់ត្រាច ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០០២ ដោយមានចំណារឯកភាពរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កំពត** ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០០៣

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

## ស ំ រេ ច

**ប្រការ១** : បើកសាលាបឋមសិក្សា **វត្តព្រែកក្រើស** ជាសាលាបឋមសិក្សាពេញលក្ខណៈ ដែលមានទីតាំងស្ថិតនៅភូមិ **ព្រែកព្លស** ឃុំ **ព្រែកក្រើស** ស្រុក **កំពង់ត្រាច** ខេត្ត **កំពត** ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២** : សាលាបឋមសិក្សា **វត្តព្រែកក្រើស** ត្រូវដឹកនាំដោយ នាយក១រូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេង ៗ ស្របតាមបទដ្ឋានប្រើប្រាស់ ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣** : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កំពត** ការិយាល័យអប់រំ យុវជន និង កីឡាស្រុក **កំពង់ត្រាច** នាយកសាលាបឋមសិក្សា **វត្តព្រែកក្រើស** មានភារកិច្ច អនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៣

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

**អ៊ឹម សិទ្ធី**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត **កំពត**

**"ដើម្បីជូនជ្រាបជាពត៌មាន"**

-ដូចប្រការ ៤

-កាលប្បវត្តិ-ឯកសារ នា.បស